**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**សម្តេចពិជ័យសេនា ទៀ បាញ់**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សូមគោរពជូន**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា**

**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន**

ជាបឋម ខ្ញុំនិងភរិយា សូមអនុញ្ញាតសម្តែងនូវអំណរគុណប្រកបដោយការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន និងសហការី** ដែលបានផ្ញើនូវសារលិខិតអំណរសាទរដ៏កក់ក្តៅបំផុត ក្នុងឱកាសដែលរូបខ្ញុំ បានទទួលនូវគោរមងារជា **សម្តេចពិជ័យសេនា ទៀ បាញ់** ដែលជាការប្រោសប្រទានដ៏ឧត្តុង្គឧត្តម នៃ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

ដើម្បីឲ្យសក្តិសមទៅនឹងព្រះរាជគោរមងារដ៏វិសេសវិសាលនេះ ខ្ញុំសូមសន្យាថា នឹងខិតខំបំពេញគ្រប់ភារកិច្ចបម្រើ ជាតិ សាសនា ព្រះមហាក្សត្រ និងប្រជាជន ព្រមទាំងកងយោធពលខេមរភូមិន្ទ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងជម្រុញការចូលរួមចំណែក ជួយឧបត្ថម្ភគាំទ្រទាំងកម្លាំងកាយ កម្លាំងចិត្ត ទាំងសម្ភារៈបច្ចេកទេស និងថវិកា ជូនកាកបាទក្រហមកម្ពុជា ឲ្យកាន់តែមានលទ្ធភាពពង្រីកកិច្ចប្រតិបត្តិការ សម្រាប់ដំណើរការសកម្មភាពមនុស្សធម៌ ឆ្លើយតបបានទាន់ពេលវេលា ទៅនឹងសេចក្តីត្រូវការចាំបាច់ មិនអាចខ្វះបានរបស់ជនរងគ្រោះ ដោយសារគ្រោះមហន្តរាយផ្សេងៗ ។

ខ្ញុំសូមប្រសិទ្ធពរជូន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា និងសហការី សូមប្រកបដោយសុខភាពបរិបូរណ៍ និងជោគជ័យដ៏ត្រចះត្រចង់លើគ្រប់ភារកិច្ចជាដរាបតរៀងទៅ ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧

**ទៀ បាញ់**